ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ ៥៧០ "ថ" ក្រ៦
ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២២
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៦
ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ២៩០
ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ១៥៨១
ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

បានបើកសវនាការនៅថ្ងៃសុក្រ ៦រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃព្រហស្បតិ៍ ១៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ ដោយមានសមាសភាពជំនុំជម្រះ៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៣៦៦ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ១៩ឆ្នាំ កើតថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរសិស្សថ្នាក់ទី១២ ទីកន្លែងកំណើតនៅភូមិ [redacted] រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិថ្នលគោលទី១ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សំអាត "រ" ម្តាយឈ្មោះ [redacted] ស្រីអូន "រ" នៅលីវ ជានីតិជន ទោសពីមុន គ្មាន។

ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ៥០៥ "ញ"ដពស ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៦៨៧"ញ"ដឃដ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

ដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ២៤០២ "ញ"ដឃដ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

២-ឈ្មោះ [redacted] ចែ ភេទប្រុស អាយុ១៩ឆ្នាំ កើតថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០០ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរអង្គការ កំរិតវប្បធម៌ថ្នាក់ទី៩ ទីកន្លែងកំណើតនៅភូមិ[redacted] រាជធានីភ្នំពេញ មុខរបរជាងសាក់ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិថ្មគោលទី១ សង្កាត់ចោមចៅទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ចែ "រ" ម្តាយឈ្មោះ [redacted] នាង "ស" នៅលីវ ជានីតិជន ទោសពីមុន គ្មាន។

ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ៥០៦ "ញ"ដពស ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៦៨៨"ញ"ដយដ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២

ដីកាសម្រេចរក្សាជនត្រូវចោទឱ្យនៅជាប់ឃុំបណ្តោះអាសន្នលេខ២៤០១ "ញ"ដយដ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

ជាប់ចោទពីបទៈ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

លោក[redacted]ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

អង្គហេតុនៃរឿងអាទិភាពនៅ

កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៧និង៣០នាទី ឈ្មោះ [redacted] ចែ បានជិះម៉ូតូម៉ាក SUZUKI NEX ពណ៌ក្រហមលាយស សេរីឆ្នាំ២០២១ ពាក់ស្លាកលេខ ភ្នំពេញ 1JA-4905 ឌុបឈ្មោះ [redacted] សុវណ្ណារ៉ា ចំណែកគូកន២នាក់ទៀតមិនស្គាល់ឈ្មោះ ជិះម៉ូតូម៉ាក SUZUKI NEX ពណ៌ស ចេញពីក្នុងបុរីពិភពថ្មី ផ្លូវវេងស្រេង ស្ថិតក្នុងភូមិត្រពាំងថ្លឹង៤ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ក្នុងគោលបំណងលួចទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋតាមផ្លូវសាធារណៈ។ លុះពេលជិះមកដល់ចំណុចតាមបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នឹងគូកនរបស់ឈ្មោះ [redacted] សុវណ្ណារ៉ា បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនមិនស្គាល់ឈ្មោះបានសម្រេច ហើយឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] ចែ ដែលជាអ្នកជិះបិទគូថពីក្រោយនាំគ្នាជិះគេចខ្លួន។ លុះដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ កម្លាំងសមត្ថកិច្ចរបស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] សុវណ្ណារ៉ា និងឈ្មោះ[redacted] ចែ យកមកធ្វើការសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ចំណែកគូកនបានគេចខ្លួន។ បន្ទាប់មកសមត្ថកិច្ចបានកសាងសំណុំរឿង បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី។

- បានឃើញ របាយការណ៍សំយោគលេខ ០១៤/២២រ.ប.ក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ២៩៧អយគ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ៩៣៤អ.ឃ.ក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៤៥៣"ញ"ដ.ដ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ដោយសារសេចក្តីអាក្រក់

ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា បានឆ្លើយថា ខ្ញុំសូមបដិសេធចម្លើយនៅប៉ូលិស ព្រោះក្នុងរឿងនេះខ្ញុំពុំបានប្រព្រឹត្ត កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ នៅចំណុចបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ខ្ញុំស្គាល់ឈ្មោះ [redacted] ចែ ព្រោះវាជាបងប្អូនជីដូនមួយខ្ញុំ។ ចម្លើយនៅប៉ូលីសកើតឡើងដោយសារការបង្ខំ ទើបខ្ញុំចេះតែឆ្លើយទៅ។ ខ្ញុំមិនស្គាល់អ្នកឆក់ទូរស័ព្ទទេ អ្នកដែលឆក់បានទូរស័ព្ទនោះបានឱ្យលុយខ្ញុំចំនួន ១៥$ (ដប់ប្រាំ) ដុល្លារអាមេរិក តែខ្ញុំមិនបានឱ្យទៅអាចែទេ។ មូលហេតុដែលគេឱ្យខ្ញុំ ១៥$ (ដប់ប្រាំ) ដុល្លារអាមេរិក ព្រោះគេខ្ចីខ្ញុំទើបសងខ្ញុំវិញ។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារ៉ា** នៅសមត្ថកិច្ចថា បានជាសមត្ថកិច្ចនគរបាលឃាត់ខ្លួន ពីព្រោះកន្លងមកខ្ញុំបាទធ្លាប់ធ្វើសកម្មភាពឆក់ជាមួយបក្ខពួកចំនួន០៣នាក់ទៀត ១-ឈ្មោះ [redacted] ចែ ហៅ ចែ ភេទប្រុស និងបក្ខពួកចំនួន០២នាក់ទៀត មិនស្គាល់ឈ្មោះ ជាមិត្តភ័ក្តិរបស់ឈ្មោះ [redacted] ចែ ហៅ ចែ ដោយធ្វើសកម្មភាពឆក់នៅខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ កាលពីថ្ងៃមិនចាំ ក្នុងខែកញ្ញា ឆ្នាំ២០២១ ពេលល្ងាច ដោយខ្ញុំជិះម៉ូតូជាមួយឈ្មោះ [redacted] ចែ ហៅ ចែ ចាំបិទគូថ។ ហើយឈ្មោះ [redacted] ចែ ហៅ ចែ បានជិះម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ក្រហមណាយស សេរីឆ្នាំ២០២១ ពាក់ស្លាកលេខ ភ្នំពេញ 1JA-4905 (ជាម៉ូតូរបស់ខ្ញុំបាទ) ដឹកខ្ញុំបាទ ចំណែកបក្ខពួកចំនួន០២នាក់ទៀតមិនស្គាល់ឈ្មោះ បានជិះម៉ូតូ០១គ្រឿង ម៉ាក SUZUKI NEX ពណ៌ស មិនចាំសេរីឆ្នាំ និងស្លាកលេខ បាននាំគ្នាជិះម៉ូតូចេញពីក្នុងបុរីពិភពថ្មី ផ្លូវចោមចៅ ហៅវែងស្រែង បត់ឡើងតាមផ្លូវបេតុង វត្តអង្គតាម៉ិញ សំដៅមកផ្លូវលេខ២០០៤ រួចបត់ចូលផ្លូវសហព័ន្ធរុស្សី ក្នុងទិសដៅពីកើតទៅលិច ហើយបក្ខពួកចំនួន០២នាក់ទៀត បានបបួលថា: តោះទៅរកលុយ ដោយប្រាប់អោយខ្ញុំបាទ និងឈ្មោះ [redacted] ចែ ហៅ ចែ គ្រាន់តែជិះម៉ូតូចាំបិទគូថ នៅពីខាងក្រោយ ចាំពួកវា ជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទដៃគេតាមផ្លូវសាធារណៈ។ លុះមកដល់ចំណុចខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហួសថ្នល់រថភ្លើង ទៅលិចបន្តិច ក្នុងសង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ ម្តុំមានហាងចិនបើកច្រើន ស្រាប់តែបក្ខពួកខ្ញុំបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃ០១គ្រឿងពីជនរងគ្រោះម្នាក់ ជាមនុស្សប្រុស ដើរតាមផ្លូវបានសំរេច ប៉ុន្តែពុំដឹងថា ពួកវាឆក់បានទូរស័ព្ទដៃម៉ាកអ្វីនោះទេ រួចពួកវាបានជិះម៉ូតូយ៉ាងលឿនគេចខ្លួនបាត់ ដោយខ្ញុំបាទ និងឈ្មោះ [redacted] ចែ ហៅ ចែ ជិះម៉ូតូតាមមិនទាន់នោះទេ បានមួយសន្ទុះក្រោយមកពួកវាបានទូរស័ព្ទមកណាត់ជួបគ្នា នៅក្នុងបុរីពិភពថ្មី ផ្លូវចោមចៅ ហៅ ផ្លូវវែងស្រែង ហើយពួកវាក៏ជិះម៉ូតូមកដល់កន្លែងណាត់ ដោយប្រាប់ថា ទូរស័ព្ទដៃដែលឆក់បានមុននេះ គឺយកទៅលក់បានលុយតែចំនួន ៩០$ (កៅសិប) ដុល្លារអាមេរិក រួចពួកវាបានចែកលុយអោយខ្ញុំបាទចំនួន១៥$ (ដប់ប្រាំ) ដុល្លារអាមេរិក ហើយក៏បែកផ្លូវគ្នារៀងៗខ្លួន។ នៅថ្ងៃទី២០ ខែមករា ឆ្នាំ

២០២២។ វេលាម៉ោង១៥និង០០នាទី ខ្ញុំបាទកំពុងតែអង្គុយផឹកកាហ្វេ នៅក្នុងបុរីពិភពថ្មី ផ្លូវចោមចៅ ហៅ ផ្លូវវ៉ែងស្រែង ស្រាប់តែឃើញកម្លាំងសមត្ថកិច្ចនគរបាលបានឃាត់ខ្លួនបក្ខពួកដែលធ្លាប់ស្គាល់គ្នា មានឈ្មោះ [redacted] សុឃាង ហៅ នី និងឈ្មោះ [redacted] ប៊ុនថេង ភេទប្រុស ដែលបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃគេតាមផ្លូវសាធារណៈ មកដល់កន្លែងដែលខ្ញុំបាទអង្គុយផឹកកាហ្វេ នៅពេលឃើញដូច្នេះ ទើបខ្ញុំបាទបានស្ទុះងើប ដើម្បីរត់គេចខ្លួន ប៉ុន្តែត្រូវបានកម្លាំងសមត្ថកិច្ចនគរបាល ឃាត់ខ្លួនខ្ញុំបាទ និងនាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌ នៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យតែម្តង។ រយៈពេលកន្លងមក ខ្ញុំបាទជាមួយបក្ខពួក ១-ឈ្មោះ [redacted]ចែ ហៅ ចែ ភេទប្រុស និងបក្ខពួកចំនួន០២នាក់ទៀតមិនស្គាល់ឈ្មោះនិងទីលំនៅ ធ្លាប់ធ្វើសកម្មភាព ជិះម៉ូតូឆក់ទូរស័ព្ទដៃគេតាមផ្លូវ បានចំនួន០១លើក (មិនចាំថ្ងៃ ក្នុងខែកញ្ញា ឆ្នាំ២០២១) ដោយខ្ញុំជាអ្នកបិទគូថ ហើយនៅម្តុំខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្នុងសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ រយៈពេលកន្លងមកខ្ញុំបាទពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ហើយគ្មៀងញៀន ក៏ខ្ញុំបាទមិនចេះជក់នោះដែរ។

ជនជាប់ចោទឈ្មោះ [redacted] ចែ បានឆ្លើយថា៖ ខ្ញុំនិងឈ្មោះ [redacted] សុវណ្ណារ៉ា គឺជាបងប្អូនជីដូនមួយគ្នា មិនសូវឧស្សាហ៍ទៅណាមកណាជាមួយគ្នាទេ យូរៗដើរលេងជាមួយគ្នាម្តងតែប៉ុណ្ណោះ។ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ នៅចំណុចបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ខ្ញុំជាមួយនឹងឈ្មោះ [redacted] សុវណ្ណារ៉ា មិនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីជនរងគ្រោះដែលកំពុងដើរតាមផ្លូវទេ។ ចំពោះចម្លើយដែលឆ្លើយនៅប៉ូលីសកើតដោយសារការបង្ខំតែប៉ុណ្ណោះ ខ្ញុំសូមបដិសេធចោល។ ខ្ញុំមិនបានទទួលប្រាក់ពីឈ្មោះ [redacted] សុវណ្ណារ៉ា ទេ។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចែ នៅសមត្ថកិច្ចថា៖ បានជាសមត្ថកិច្ចនគរបាលឃាត់ខ្លួន ពីព្រោះកន្លងមកខ្ញុំបាទធ្លាប់ធ្វើសកម្មភាពឆក់ជាមួយបក្ខពួកចំនួន០៣នាក់ទៀត ១-ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស និងបក្ខពួកចំនួន០២នាក់ទៀត មិនស្គាល់ឈ្មោះ និងទីលំនៅ ដោយធ្វើសកម្មភាពឆក់នៅខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ កាលពីថ្ងៃមិនចាំ ក្នុងខែកញ្ញា ឆ្នាំ២០២១ ពេលល្ងាច ដោយខ្ញុំជិះម៉ូតូជាមួយឈ្មោះ [redacted] ចែ ហៅ ចែ ចាំបិទគូថ។ ហើយខ្ញុំបាទបានជិះម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ក្រហមលាយស សេរីឆ្នាំ២០២១ ពាក់ស្លាកលេខ ភ្នំពេញ 1JA-4905 (ជាម៉ូតូរបស់ឈ្មោះ [redacted] សុវណ្ណារ៉ា) ដឹកឈ្មោះ [redacted] សុវណ្ណារ៉ា ចំណែកបក្ខពួកចំនួន០២នាក់ទៀតមិនស្គាល់ឈ្មោះ បានជិះម៉ូតូ០១គ្រឿងម៉ាក SUZUKI NEX ពណ៌ស មិនចាំសេរីឆ្នាំ និងស្លាកលេខ បាននាំគ្នាជិះម៉ូតូចេញពីក្នុងបុរីពិភពថ្មី ផ្លូវចោមចៅ ហៅផ្លូវវ៉ែងស្រែង បត់ឡើងតាមផ្លូវបេតុង វត្តអង្គតាមុិញ សំដៅមកផ្លូវលេខ២០០៤ រួចបត់ចូលផ្លូវសហព័ន្ធរុស្សី ក្នុងទិសដៅពីកើតទៅលិច ហើយបក្ខពួកចំនួន០២នាក់ទៀត បានបបួលថា តោះទៅរកលុយ ដោយប្រាប់ឱ្យខ្ញុំបាទ និងឈ្មោះ [redacted] សុវណ្ណារ៉ា គ្រាន់តែជិះម៉ូតូចាំបិទគូថនៅពីខាងក្រោយចាំពួកវាជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទដៃគេ តាមផ្លូវសាធារណៈ។ លុះមកដល់ចំណុចខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហួសថ្នល់រថភ្លើងទៅលិចបន្តិច ក្នុងសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ ម្តុំមានហាងចិនបើកច្រែន ស្រាប់តែបក្ខពួកខ្លួនបានធ្វើសកម្មភាពឆក់

ទូរស័ព្ទដៃ១គ្រឿងពីជនរងគ្រោះម្នាក់ ជាមនុស្សប្រុសដើរតាមផ្លូវបានសំរេច ប៉ុន្តែពុំដឹងថាពួកវាឆក់បានទូរស័ព្ទដៃម៉ាកអ្វីនោះទ រួចពួកវាបានជិះម៉ូតូយ៉ាងលឿនគេចខ្លួនបាត់ ដោយខ្ញុំបាទនិងឈ្មោះ [redacted] សុវណ្ណារ៉ា ជិះម៉ូតូតាមមិនទាន់នោះទេ បានមួយសន្ទុះក្រោយមកពួកវាបានទូរស័ព្ទមកណាត់ជួបគ្នានៅក្នុងបុរីពិភពថ្មី ផ្លូវចោមចៅ ហៅផ្លូវវែងស្រែង ហើយពួកវាក៏ជិះម៉ូតូមកដល់កន្លែងណាត់ ដោយឈប់ម៉ូតូនិយាយលេង បានមួយសន្ទុះក្រោយមកក៏បែកផ្លូវគ្នារៀងៗខ្លួន នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង១៥និង០០នាទី ខ្ញុំបាទកំពុងតែអង្គុយផឹកកាហ្វេនៅក្នុងបុរីពិភពថ្មី ផ្លូវចោមចៅ ហៅ ផ្លូវវែងស្រែង ស្រាប់តែឃើញកម្លាំងសមត្ថកិច្ចនគរបាល បានឃាត់ខ្លួន បក្ខពួកដែលធ្លាប់ស្គាល់គ្នា មានឈ្មោះ [redacted] សុឃាង ហៅ នី និងឈ្មោះ [redacted] ប៊ុនថេង ភេទប្រុស ដែលបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃគេតាមផ្លូវសាធារណៈ មកដល់កន្លែងដែលខ្ញុំបាទអង្គុយផឹកកាហ្វេ ដោយមានការសង្ស័យទើបកម្លាំងសមត្ថកិច្ចនគរបាលឃាត់ខ្លួនខ្ញុំបាទ និងនាំយកមកសាកសួរនៅផ្នែកនគរបាលយុត្តិធម៌ នៃអធិការដ្ឋាននគរបាល ខណ្ឌពោធិ៍សែនជ័យ តែម្តង។ រយៈពេលកន្លងមកខ្ញុំបាទជាមួយបក្ខពួក ១-ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស និងបក្ខពួកចំនួន០២នាក់ទៀតមិនស្គាល់ឈ្មោះ និងទីលំនៅ ធ្លាប់ធ្វើសកម្មភាពជិះម៉ូតូឆក់ទូរស័ព្ទដៃគេតាមផ្លូវបានចំនួន០១លើក (មិនចាំថ្ងៃ ក្នុងខែកញ្ញា ឆ្នាំ២០២១) ដោយខ្ញុំជាអ្នកបិទគូថ ហើយនៅម្តុំខាងមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្នុងសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ រយៈពេលកន្លងមកខ្ញុំបាទពុំធ្លាប់ជាប់ពន្ធនាគារនោះទេ ហើយគ្មើងញៀន ក៏ខ្ញុំបាទមិនចេះជក់នោះដែរ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ អំណានចម្លើយរបស់ជនជាប់ចោទ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ៩៣៤អ.ឃ.ក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

កូនក្តីខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយចំពោះចម្លើយដែលគាត់ធ្វើឡើយនៅប៉ូលិសកើតឡើងដោយដារបង្ខិតបង្ខំតែប៉ុណ្ណោះ ហេតុនេះខ្ញុំស្នើតុលាការសម្រេចឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទ។

សំដីចុងក្រោយរបស់ជនជាប់ចោទ

ឈ្មោះ [redacted] **សុវណ្ណារ៉ា** បានស្នើសុំតុលាការជួយរកយុត្តិធម៌។

ឈ្មោះ [redacted] **ចែ** បានស្នើសុំតុលាការជួយរកយុត្តិធម៌។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ និងភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាដំបូងរាជធានីភ្នំពេញ

យល់ឃើញថា

១-ចៅក្រមស៊ើបសួរបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារ៉ា** និងជនជាប់ចោទឈ្មោះ [redacted] **ចែ** មកជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។ តុលាការអាចយកវឿងនេះ មកជំនុំជម្រះតាមមាត្រា ២០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា ជនជាប់ចោទពិតជាបានប្រព្រឹត្ត ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន។ ហេតុដូច្នេះ តំណាងអយ្យការសុំរក្សាការចោទប្រកាន់ និងតម្កល់ដីកាសន្និដ្ឋានស្តាពររបស់តំណាងអយ្យការទុកជាបានការដដែល និងប្តឹងសុំចៅក្រមជំនុំជម្រះ ពិចារណាផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។ ចំពោះសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ គឺមានភាពសមស្រប ដែលតុលាការអាចយកមកពិនិត្យ និងសម្រេចតាមផ្លូវច្បាប់បាន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារ៉ា** និងជនជាប់ចោទឈ្មោះ [redacted] **ចែ** បានឆ្លើយបដិសេធថា៖ ពួកខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ។ នៅថ្ងៃកើតហេតុនោះពួកខ្លួនមិនបានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះឡើយ។ ចម្លើយបដិសេធរបស់ជនជាប់ចោទ គ្មានមូលដ្ឋានសម្រាប់តុលាការពិចារណាឡើយ។ ជនជាប់ចោទបញ្ជាក់នាពេលសវនាការថា ចម្លើយដែលខ្លួនឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌កើតឡើងដោយសារការបង្ខំ ប៉ុន្តែជនជាប់ចោទពុំបានបង្ហាញភស្តុតាងពីរបៀបនៃការបង្ខំ ឬការបង្ខំដោយរបៀបណាមួយនោះក៏គ្មានដែរ ហេតុនេះសម្តីរបស់ជនជាប់ចោទគ្រាន់តែជាការលើកឡើងដោយគ្មានមូលដ្ឋានសម្រាប់ឱ្យតុលាការពិនិត្យ និងពិចារណារឡើយនាពេលសវនាការ ជនជាប់ចោទបានទទួលស្គាល់ថា អ្នកដែលឆក់ទូរស័ព្ទបានឱ្យលុយមកខ្លួន ១៥$ (ដប់ប្រាំ) ដុល្លារអាមេរិក ជាលុយដែលគេខ្ចីខ្លួន ហើយបានបដិសេធពីការមានទំនាក់ទំនងស្គាល់គ្នា។ ត្រង់ចំណុចនេះអាចឱ្យតុលាការកំណត់បានថា ជនជាប់ចោទ និងជនល្មើសដែលគេចខ្លួនគឺជាក្រុមតែមួយ ដែលផ្ទុយពីការអះអាងរបស់ជនជាប់ចោទ ព្រោះជនជាប់ចោទបានផ្តល់សក្ខីកម្មនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដោយបានទទួលស្គាល់នូវរាល់សកម្មភាពដែលពួកខ្លួនបានប្រព្រឹត្ត ដែលសក្ខីកម្មនោះ មិនបានស្ថិតក្រោមរូបភាពនៃការបង្ខិតបង្ខំណាមួយឡើយ ដូច្នេះវាមានតម្លៃជាភស្តុតាងសម្រាប់តុលាការពិចារណា។ ដូច្នេះអាចឱ្យតុលាការកំណត់បានពីអំពើរបស់ជនជាប់ចោទទាំងពីរ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តកាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១។

៤-យោងតាមមាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ ចែងថា “អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់

ខ្លួន" ហើយមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ចែងថា "អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណីដូចតទៅ៖ ១.អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា។ ២.អំពើលួចនេះ ប្រព្រឹត្តដោយការកាប់គាស់ទម្លុះទម្លាយ" ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ **សំអាង សុវណ្ណារ៉ា** និងជនជាប់ចោទឈ្មោះ [redacted] ចែ ដែលបានឆក់ទូរស័ព្ទដៃរបស់ជនរងគ្រោះ យកទ្រព្យសម្បត្តិរបស់គេមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន នោះគឺជាអំពើ ហិង្សា ដែលអំពើបែបនេះច្បាប់កំណត់ថាជាបទល្មើស លួចមានស្តានទម្ងន់ទោស តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៥-ជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា និងជនជាប់ចោទឈ្មោះ [redacted] ចែ ជាសមត្ថជនដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ពោលគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជននេះមានបញ្ហាខាងស្មារតីឡើយ នាពេលកំពុងប្រព្រឹត្តបទល្មើស ដូចនេះជនជាប់ចោទពិតជាមានស្មារតីធម្មតាក្នុងពេលប្រព្រឹត្តបទល្មើស និងអាចយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន។

៦-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ដែលបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទ ឈ្មោះ [redacted] **សុវណ្ណារ៉ា** និងជនជាប់ចោទឈ្មោះ [redacted] ចែ ពីបទ **លួចមានស្តានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

៧-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានមូលដ្ឋានសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៨-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ និងការស្នើសុំរបស់ជនជាប់ចោទ ក្រុមប្រឹក្សាបានពិចារណារួចហើយ។

៩-តាមការពិនិត្យលើអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **សុវណ្ណារ៉ា** និងជនជាប់ចោទឈ្មោះ [redacted] **ចែ** ឃើញថា ជនជាប់ចោទបានធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ និងបង្កឱ្យមានចលាចលក្នុងសង្គម ដូចនេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

១០-វត្ថុចាប់យកមាន៖ ម៉ូតូចំនួន១គ្រឿង ម៉ាក SUZUKI NEX ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1JA-4905 ដកហូតពីឈ្មោះ [redacted] សុវណ្ណារ៉ា ត្រូវបានប្រគល់តាមដីកាបង្គាប់ឱ្យប្រគល់វត្ថុចាប់យកទៅម្ចាស់ដើមវិញលេខ ០០៦ អយគ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ហេតុនេះតុលាការពុំពិចារណា។

១១-នៅក្នុងរឿងនេះជនជាប់ចោទបានបង្កឱ្យមានព្យសនកម្មលើជនរងគ្រោះ ដោយការឆក់ទូរស័ព្ទរបស់ជនរងគ្រោះ ប៉ុន្តែជនរងគ្រោះពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងឡើយ ហេតុនេះគប្បីតុលាការមិនពិចារណា។

ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ចែ ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ៤ (បួន) ឆ្នាំ។

ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចតាមបណ្តោយផ្លូវសហព័ន្ធរុស្សី ស្ថិតក្នុងភូមិក្បាលដំរី២ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីអំឡុងខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា៖	ហត្ថលេខា និងត្រា៖	ហត្ថលេខា និងត្រា៖	ហត្ថលេខា និងត្រា៖
[redacted]			

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។"

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]